ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ..១២៣៣..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីចំនួនមួយចំណែកនៃដីស្ពាយ ខេត្តកំពង់ចាម

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស /រកម/០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ស្តីពីការប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៨០៦/៣៣៧ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និង បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩អនក្រ.បក ចុះថ្ងៃទ ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគ ទ្រព្យសម្បត្តិ សាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-យោងលិខិតលេខ ១៩៤៣ សជណ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

-យោងលិខិតលេខ ៣២១ លខ.កច ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០០៨ របស់សាលាខេត្តកំពង់ចាម

-យោងលិខិតលេខ ៦០១/០៨ ដនសស.កច ចុះថ្ងៃ ទី ៣០ ខែ មេសា ឆ្នាំ ២០០៨ របស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និង សុរិយោដី ខេត្តកំពង់ចាម ។

## សម្រេច

មាត្រា ១.-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវទីតាំងបឹងស្នាយខេត្តកំពង់ចាម មួយចំណែក ដែលមានផ្ទៃដីទំហំ ១០៧.៦៧ ហិកតា "មួយរយប្រាំពីរហិកតា និងហុកសិបប្រាំពីរអា" នៃផ្ទៃបឹងសរុបទំហំ១២៦.១០ ហិកតា "មួយរយម្ភៃប្រាំមួយហិកតា និងដប់អា" ស្ថិតនៅតាមផ្លូវជាតិលេខ ៧ ជាប់ខាងលិចទីប្រជុំជនស្រុកកំពង់ចាម និង ស្ថិតក្នុង ឃុំចំនួនពីរ របស់ស្រុកកំពង់ចាម គឺ ឃុំសំបួរមាស ដោយរួមមានភូមិ ៤ ភូមិបឹងស្នាយ ភូមិបឹងបាសាក់ ភូមិ ព្រៃកចាន់ ភូមិនាងគង្ហីង និង ឃុំវាលវង់ រួមមានភូមិពីរ ភូមិទី ១ និងភូមិទី៦ ។

មាត្រា ២.-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគខាងលើនេះ ត្រូវស្ថិតក្រោមការចាត់ចែង នីតិវិធីបន្ត ដោយក្រសួងដែនដីនគរូបនីយកម្ម និង សំណង់ ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលាខេត្តកំពង់ចាម ដោយសហការជាមួយក្រុមហ៊ុនដៃគូអភិវឌ្ឍន៍ ស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ដែលបានចែងក្នុងលិខិតលេខ ១៩៤៣ ស ជ ណ ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ៣.-

ត្រូវបានផ្តល់ជូនដៃគូអភិវឌ្ឍន៍ នូវផ្ទៃដីចំនួន ៦៤៦.០២០ "ប្រាំមួយរយសែសិបប្រាំមួយពាន់ម្ភៃ" ម៉ែត្រក្រឡា ។ ផ្ទៃដីទំហំ ៤៣០.៦៨០ "បួនរយសាមសិបពាន់ប្រាំមួយរយប៉ែតសិប " ម៉ែត្រក្រឡា ដែលជាចំណែករបស់រដ្ឋ ត្រូវកត់ត្រាទៅក្នុងបញ្ជីសារពើភ័ណ្ឌ ជាទ្រព្យសម្បត្តិរដ្ឋរបស់សាលាខេត្តកំពង់ចាម ។

មាត្រា ៤.-

ការបំពេញបែបបទធ្វើកម្មសិទ្ធិត្រូវប្រព្រឹត្តទៅតាមច្បាប់ និង គោលការណ៍កំណត់ជាធរមាន ។

មាត្រា ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០០៨

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ដូចមាត្រា ៦
- ឯកសារ-កាលប្បវត្តិ